រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

033KH01A-01

កិច្ចការរបស់ព្រះជាម្ចាស់ជាព្រះវិញ្ញាណដ៏វិសុទ្ធ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៣៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់បំភ្លឺចិត្តគំនិត និងប្រាជ្ញារបស់អ្នក
ពេលអ្នកសិក្សាកូនសៀភៅនេះ ។

ការសិក្សានេះមានបួនផ្នែក ។ ផ្នែកទីមួយ ទាក់ទងនឹងសញ្ញាដៅ
សំគាល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ការទទួលព្រះវិញ្ញាណដ៏វិសុទ្ធ
បញ្ជាក់ថា យើងជាកូនរបស់ព្រះជាម្ចាស់ ។ ផ្នែកទីពីរ គឺការ
សិក្សារៀបរាប់អំពីផលផ្លែរបស់ព្រះវិញ្ញាណ ។ ផលផ្លែទាំងនោះ
ជាចរិតលក្ខណៈរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលព្រះវិញ្ញាណ
ដ៏វិសុទ្ធបង្កើតអោយមានក្នុងយើង ។ ផ្នែកទីបី គឺការពន្យល់ពី
របៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់ក្នុងយើង ប្រទានអោយ
យើងមានឫទ្ធានុភាព ដើម្បីផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ។ ផ្នែក
ទីបួន គឺរៀបរាប់ប្រាប់យើងអំពីអំណោយទានរបស់ព្រះវិញ្ញាណដ៏
វិសុទ្ធ ។



កំណត់ចំណាំ

© Project WorldReach © SEAN

ផ្នែក ទី ១

សញ្ញាដៅសំគាល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ

នៅពេលដែលយើងជឿលើព្រះគ្រីស្ត ព្រះជាម្ចាស់បញ្ជាក់ថាយើងបានសង្គ្រោះអស់កល្ប ដោយសារសញ្ញាសំគាល់ ដែលជាវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ យើងហៅវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធថា « សញ្ញាដៅសំគាល់ » ពីព្រោះវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបញ្ជាក់ និង ធានាថា យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ និងជាអ្នកទទួលមរតករួមជាមួយព្រះយេស៊ូគ្រីស្ត (យ៉ូហាន ៧:៣៧-៣៩, រ៉ូម ៨:៩-១៧, ២ កូរិនថូស ១:២១-២២) ។

« ដោយរួមក្នុងអង្គព្រះគ្រីស្ត បងប្អូនបានស្តាប់ព្រះបន្ទូលនៃសេចក្តីពិតជាដំណឹងល្អដែលសង្គ្រោះបងប្អូន ។ ក្នុងអង្គព្រះគ្រីស្ត បងប្អូនក៏បានជឿ ហើយបានទទួលសញ្ញាដៅសំគាល់ពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមព្រះបន្ទូលសន្យាដែរ ។ ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណនេះមកបញ្ចាំចិត្តយើងអោយដឹងថា យើងនឹងទទួលមរតក នៅពេលព្រះអង្គលោះប្រជារាស្ត្ររបស់ព្រះអង្គជាស្ថាពរ ដើម្បីអោយគេលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ » ។

(អេភេសូ ១:១៣-១៤)

កំណត់ចំណាំ

នៅក្នុងសម្ពន្ធមេត្រីចាស់ អ្នកបំរើរបស់ព្រះជាម្ចាស់តែងតែបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបំពេញភារៈកិច្ចពិសេសៗ (ឧទាហរណ៍ សេរីភាព ៣១:៣) ។ នៅក្នុងសម្ពន្ធមេត្រីថ្មី នៅពេលបុណ្យថែទីហាសិប នៅក្នុងកិច្ចការ ចំពូក ២ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកគង់ជាប្រចាំជា "**ព្រះដ៏ជួយការពារ (លួងលោមចិត្ត)**" ។ ព្រោះប៉ុន្មានថៃមុននេះ ព្រះយេស៊ូគ្រីស្តបានយាងទៅស្ថានបរមសុខ និង បានសន្យាថា នឹងចាត់ព្រះដ៏ជួយការពារអោយមកគង់ជាមួយយើង និង រស់ក្នុងយើងជា**រៀងរហូតតទៅ** (យ៉ូហាន ១៤:១៥-១៧) ។ ព្រះដ៏ជួយការពារប្រទានកម្លាំងអោយយើង និង ជួយយើងអោយអធិស្ឋាន ។

សញ្ញាដៅសំគាល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ មានចំណុចសំខាន់ច្រើនយ៉ាង ដែលយើងនឹងសិក្សានៅក្នុងទំព័របន្តបន្ទាប់ទៀតនេះ ។

សូមគូសសញ្ញា «✓» នេះ ក្នុង «☐» នៅពេលដែល អ្នកបានអានវគ្គព្រះគម្ពីរទាំងនេះចប់ :

☐ យ៉ូហាន ១៤:១៥-២១

☐ យ៉ូហាន ១៥:២៦-២៧

កំណត់ចំណាំ

© Project WorldReach © SEAN

- ពន្យល់អំពីអំណោយទានផ្សេងៗ ហើយជួយសមាជិកអោយអាចទទួលស្គាល់អំណោយទានទាំងនោះ ដើម្បីអនុវត្តការបំរើតាមអំណោយទាននិមួយៗនោះ ។ របៀបមួយដែលនាំអោយអាចដឹងពីអំណោយទានរបស់យើង គឺធ្វើកិច្ចការបំរើផ្សេងៗច្រើនយ៉ាង រហូតដល់មើលដឹងថា ព្រះជាម្ចាស់ប្រើយើងអោយធ្វើកិច្ចការណាមួយខ្លាំងជាងគេ ។

_____

_____

_____

_____

- ពន្យល់អំពីគោលបំណងរបស់ទីសំគាល់ ដែលជាការបញ្ជាក់សេចក្តីសាររបស់ដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ។

_____

_____

_____

☐ យ៉ូហាន ១៦:១-១៦

☐ កិច្ចការ ១៩:១-៧

☐ កាឡាទី ៥:២១-២៦, ៦:៨ ។

ព្រះវិញ្ញាណដ៏វិសុទ្ធបង្រួបបង្រួមយើងក្នុងអង្គព្រះយេស៊ូ

ព្រះបិតាបង្រួបបង្រួមយើងជាមួយព្រះគ្រីស្ត តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ :

ព្រះគ្រីស្តប្រៀបបាននៅនឹងរូបកាយមួយ ដែលចែកចេញជាច្រើនផ្នែក ។ ទោះបីមានសរីរាង្គច្រើនយ៉ាងណាក៏ដោយ ក៏សរីរាង្គទាំងអស់ផ្សំគ្នាជារូបកាយតែមួយដែរ ។ យើងទាំងអស់គ្នា ទោះបីជាសាសន៍យូដាក្តី សាសន៍ក្រិកក្តី អ្នកងារក្តី អ្នកជាក្តី ក៏យើងបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណតែមួយ ដើម្បីផ្សំគ្នាឡើងជាព្រះកាយតែមួយ ហើយយើងទាំងអស់គ្នាសុទ្ធតែបានទទួលព្រះ-វិញ្ញាណតែមួយដែរ ។

(១ កូរិនថូស ១២:១២-១៣)

គឺថា ដោយសារដំណឹងល្អ សាសន៍ដទៃមានសិទ្ធិចូលរួមទទួលមតិក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ និងមានសិទ្ធិទទួលព្រះពរតាមព្រះបន្ទូលសន្យា រួមជាមួយសាសន៍អ៊ីស្រាអែល ក្នុងអង្គព្រះគ្រីស្តយេស៊ូ ។ (អេភេសូ ៣:៦)





ពួកអ្នកជឿលើព្រះគ្រីស្តមកពីគ្រប់ជាតិសាសន៍

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានសំរាប់ពួកសាវ័កថ្មី អោយពួកគេបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងធ្វើឱ្យផលផ្លែនៃព្រះវិញ្ញាណរីកចំរើនរាល់ថ្ងៃ ។
- បង្រៀនក្រុមជំនុំរបស់អ្នក ពីកិច្ចការរបស់ព្រះវិញ្ញាណដ៏-វិសុទ្ធ ។
- ណែនាំគ្រីស្តជនម្នាក់ៗអោយអាចជ្រើសយកផលផ្លែខ្លះរបស់ព្រះវិញ្ញាណ ដែលពួកគេត្រូវធ្វើឱ្យមានភាពកាន់តែប្រសើរឡើងក្នុងជីវិតរបស់គេ ដោយការអធិស្ឋាន និងការអប់រំខ្លួនឯង ។
- ពន្យល់ប្រាប់ក្រុមជំនុំរបស់អ្នក អំពីបុព្វានុភាពរបស់ព្រះ-វិញ្ញាណដ៏វិសុទ្ធ សំរាប់ការផ្សាយដំណឹងល្អ ។

© Project WorldReach © SEAN

៤- ពេលបានរួមជាមួយព្រះគ្រីស្ត ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយ យើងចាប់ផ្តើមមានមេត្រីភាពកាន់តែខ្លាំងឡើងៗជាមួយព្រះជាម្ចាស់ ដែលធ្វើអោយយើងក្លាយជាបរិសុទ្ធបន្តិចម្តងៗ ។ ការក្លាយទៅជាបរិសុទ្ធនេះ បង្ហាញចេញជា :

☐ ផលផ្លែនៃព្រះវិញ្ញាណ (សេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ។ល។...) ។

☐ អារម្មណ៍សប្បាយ តែមិនស្ថិតស្ថេរ ។

៥- ក្រៅពីផលផ្លែនៃព្រះវិញ្ញាណ តើព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឫទ្ធានុភាពឱ្យយើងធ្វើអ្វីផ្សេងទៀត យោងទៅតាមកិច្ចការ ១:៨ ?

ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងជឿជាក់ថា យើងបានសង្គ្រោះអស់កល្បហើយ

- **ព្រះបិតាជ្រើសរើស**យើងជាបុត្រធីតារបស់ព្រះអង្គ តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ (អេភេសូ ១:៤-៥) ។

- **ព្រះបុត្រា**បានប្រោសលោះយើងអោយក្លាយជាបុត្រធីតារបស់ព្រះអង្គ ដោយសារព្រះអង្គសុគត និងមានព្រះជន្មរស់ឡើងវិញ (លូកា ២៤:៤៦-៤៧, យ៉ូហាន ១០:១១-១៥) ។

- ឥឡូវនេះ **ព្រះវិញ្ញាណដ៏វិសុទ្ធ**ធ្វើអោយការប្រោសលោះនេះបង្កើតផលក្នុងជីវិតរបស់យើង (រ៉ូម ៨:១៤-១៦, ៨:២៦-៣០) ។

គ្រីស្តជនមានសេចក្តីសុខសាន្ត
នៅក្នុងព្រះហស្ថរបស់ព្រះជាម្ចាស់
(យ៉ូហាន ១០:២៧-៣០)



ការប្រឡង (សំនួរសង្ខេបមេរៀន)

សូមគូសសញ្ញា «✓» នេះ នៅនឹងចំលើយដែលត្រឹមត្រូវ ។

១- ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុង :

- ☐ ពួកអ្នកជឿលើព្រះយេស៊ូទាំងអស់ ។
- ☐ តែគ្រូគង្វាល និងគ្រីស្តជនរឹងមាំប៉ុណ្ណោះ ។

២- ព្រះវិញ្ញាណដ៏វិសុទ្ធបញ្ជាក់ថា យើងជាកូនរបស់ព្រះអម្ចាស់ ដោយព្រះអង្គជា :

- ☐ សញ្ញាដៅសំគាល់នៅក្នុងពួកអ្នក ដែលជារបស់ផង ព្រះជាម្ចាស់ ។
- ☐ មូលហេតុសំរាប់យកមកទិតៀនពួកអ្នកជឿទន់ខ្សោយ ។

៣- ព្រះវិញ្ញាណដ៏វិសុទ្ធបោះត្រា សំរាប់សំគាល់យើងជារបស់ ព្រះជាម្ចាស់ ។ ព្រះអង្គធ្វើអោយយើងបានរួមជាមួយ :

- ☐ មនុស្សគ្រប់រូប ។
- ☐ ព្រះអម្ចាស់យេស៊ូ ។

មនុស្សសុចរិតមានជីវិតរស់នៅ ដោយសារជំនឿ ។

(រ៉ូម ១:១៧)

...ជំនឿកើតមកពីសេចក្តី ដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះ កើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ត ។

(រ៉ូម ១០:១៧)

យើងអាចធ្វើអ្វីៗគ្រប់យ៉ាងថ្វាយព្រះជាម្ចាស់ តាមរយៈជំនឿនេះ ។

(ម៉ាកុស ១១:២៣-២៤)

នៅពេលដែលអ្នករៀនចប់មេរៀននេះរួចហើយ សូមថ្វាយសិរីល្អទៅព្រះជាម្ចាស់ ដែលបានប្រទានអំណោយទានដ៏អស្ចារ្យ គឺជាព្រះអម្ចាស់យេស៊ូគ្រីស្តរបស់យើង (២ កូរិនថូស ៩:១៥) ។

ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើង បានរួមជាមួយនឹងព្រះគ្រីស្ត

ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយពួកអ្នកជឿទាំងអស់ បានរួមជាមួយនឹងព្រះគ្រីស្ត ជារូបកាយតែមួយរបស់ «ក្រុមជំនុំ/ព្រះសហគមន៍សកលលោក» ។ ពិធីជ្រមុជទឹកជាការបញ្ជាក់ថា យើងបានរួមខាងព្រលឹងវិញ្ញាណជាមួយនឹងព្រះគ្រីស្ត និងប្រជារាស្ត្ររបស់ព្រះអង្គ (រ៉ូម ៦:១-១៤) ។ (សូមអាន «ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី») ។

«ដ្បិតបងប្អូនបានស្លាប់ផុតទៅហើយ ហើយជីវិតរបស់បងប្អូនក៏បានកប់ទុកជាមួយព្រះគ្រីស្ត ក្នុងព្រះជាម្ចាស់ដែរ»
(កូឡូស ៣:៣) ។





ពិធីជ្រមុជទឹក ជាការបង្ហាញអំពីកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយើងមិនអាចមើលឃើញ និងដែលធ្វើអោយយើងបានរួម ជាមួយព្រះគ្រីស្តផ្ទាល់ (កិច្ចការ ២:៣៨, ១៩:៥-៦, អេភេសូ ២:១៨) ។



យើងអាចដឹងថាទីសំគាល់ណាមួយមកពីព្រះជាម្ចាស់ បើសិនជាអ្នកដែលធ្វើអោយមានទីសំគាល់នេះ មានជីវិតរស់នៅបរិសុទ្ធ និងធ្វើអំពើល្អ (ម៉ាថាយ ៧:១៥-២០) ហើយបើសិនជាអ្នកនោះអធិប្បាយ ប្រកាសព្រះបន្ទូលត្រឹមត្រូវតាមព្រះគម្ពីរ (ទុតិយកថា ១៣:១-៤) ។

ព្រះគម្ពីរជាសេចក្តីបើកសំដែងពេញលេញរបស់ព្រះជាម្ចាស់ ហើយព្រះគម្ពីរត្រូវព្រះវិញ្ញាណព្រះអង្គបណ្តាលអោយសរសេរឡើង

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គ្រប់គ្រាន់ពេញលេញ សំរាប់ឱ្យយើងយល់ដឹងអំពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ ព្រមទាំងពីរបៀបបំរើព្រះអង្គ ។ យើងត្រូវស្ទង់មើលគោលជំនឿ និងការប្រតិបត្តិគ្រប់យ៉ាងតាមរយៈព្រះគម្ពីរ (អេសាយ ៨:២០) ។

ព្រះជាម្ចាស់បង្គាប់យើងអោយដើរដោយជំនឿ និងដោយទុកចិត្តលើសេចក្តីសន្យាទាំងឡាយ ដែលមានក្នុងព្រះបន្ទូលព្រះអង្គ (ហេប្រឺ ១១:៦) ។

យើងរាល់គ្នាបាននៅក្នុងព្រះគ្រីស្ត និងបានពេញដោយសិរីរុងរឿងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។



ទោះបីជាយើងស្លាប់ ដោយសារអំពើបាបរបស់យើងហើយ... ព្រះអង្គបានប្រោសយើងឱ្យអង្គុយលើបល្ល័ង្កនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ (អេភេសូ ២:៥-៦) ។

ព្រះជាម្ចាស់គង់ក្នុងយើងនៅលើផែនដីនេះតាមរយៈព្រះវិញ្ញាណរបស់ព្រះអង្គផ្ទាល់ ដែលជាសញ្ញាដៅសំគាល់ពីវត្តមានរបស់ព្រះអង្គ ។

ព្រះយេស៊ូមានព្រះបន្ទូលថា៖ «នៅថៃនោះ អ្នករាល់គ្នានឹងយើញថា ខ្ញុំនៅក្នុងព្រះបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នានៅក្នុងខ្ញុំ ខ្ញុំក៏នៅក្នុងអ្នករាល់គ្នាដែរ » (យ៉ូហាន ១៤:២០) ។

យើងបានអង្គុយជាមួយព្រះគ្រីស្តនៅស្ថានបរមសុខ ។ យើងមិនទាន់មើលឃើញផ្លូវមាស ឬ ស្តាប់សំលេងច្រៀងរបស់ពួកទេវទូតនៅឡើយទេ ពីព្រោះភ្នែក និង ត្រចៀករបស់យើង នៅជារបស់រូបកាយលោកីយ៍នៅឡើយ ប៉ុន្តែ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ យើងបាននៅក្នុងព្រះជាម្ចាស់ ហើយព្រះអង្គគង់ក្នុងយើង ។ នៅពេលដែលព្រះយេស៊ូយាងមក យើងនឹងផ្លាស់ប្រែ និងមានរូបកាយថ្មី មិនចេះស្លាប់ និង មិនពុករលួយ (១ កូរិនថូស ១៥:៥១-៥៣, ២ កូរិនថូស ៥:១-១០) ។

ទីសំគាល់ពិតប្រាកដបញ្ជាក់ដោយព្រះគម្ពីរ និងជីវិតបរិសុទ្ធ

គួរឱ្យស្តាយ អារក្សធ្វើត្រាប់តាមព្រះជាម្ចាស់ វាក៏ធ្វើការអស្ចារ្យដើម្បីបោកបញ្ឆោតមនុស្សដែរ (សេរីភាព ៧:១០-១២, ម៉ាថាយ ២៤:២៤) ។

នៅថៃនោះនឹងមានមនុស្សជាច្រើនពោលមកខ្ញុំថា៖ *« "ព្រះអម្ចាស់ ព្រះអម្ចាស់អើយ ! យើងខ្ញុំធ្លាប់ថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអង្គ យើងខ្ញុំធ្លាប់ដេញខ្មោចក្នុងព្រះនាមព្រះអង្គ ហើយយើងខ្ញុំក៏ធ្លាប់ធ្វើការអស្ចារ្យជាច្រើនក្នុងព្រះនាមព្រះអង្គដែរ ! " ។ ពេលនោះ ខ្ញុំនឹងប្រកាសប្រាប់អ្នករាល់គ្នាថា ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ ! " ចូរថយចេញអោយឆាយពីខ្ញុំទៅ ខ្ញុំមិនដែលស្គាល់អ្នករាល់គ្នាទេ ! " »* ។

(ម៉ាថាយ ៧:២២-២៣)

ទោះជាយើងដឹងថា មារសាតាំងក្លែងបន្លំធ្វើទីសំគាល់ក៏ដោយ ក៏យើងត្រូវធ្វើការអធិស្ឋានបន្តសំរាប់អ្នកជម្ងឺ ដេញខ្មោច ឬ ប្រើអំណោយទានអស្ចារ្យ ដែលព្រះជាម្ចាស់ប្រទានអោយយើងតទៅទៀតដែរ ។

នៅពេលដែលព្រះអម្ចាស់យេស៊ូធ្វើកិច្ចការបំរើព្រះជាម្ចាស់ លើផែនដី ព្រះអង្គបានបង្គាប់ដល់សាវ័ករបស់ព្រះអង្គអោយសំដែងទីសំគាល់ ដោយសារព្រះនាមព្រះអង្គ ។ ទីសំគាល់ទាំងនោះ ជាភស្តុតាងបញ្ជាក់ដំណឹងល្អ ។ «*ពេលធ្វើដំណើរទៅ ចូរប្រកាសថា ព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ ។ ចូរមើលអ្នកជំងឺអោយបានជា ប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ ធ្វើឱ្យមនុស្សឃ្លង់បានជាស្អាតបរិសុទ្ធ ដេញខ្មោចចេញពីមនុស្ស ។ អ្នករាល់គ្នាបានទទួលអំណាច ដោយឥតបង់ថ្លៃ ត្រូវជួយគេវិញដោយឥតគិតថ្លៃដែរ* » ។

(ម៉ាថាយ ១០:៧-៨)

ព្រះជាម្ចាស់បញ្ជាក់ពាក្យសំដី ដែលពួកអ្នកជឿប្រកាស នៅពេលដែលពួកគេផ្សាយដំណឹងល្អ ដោយទីសំគាល់ទាំងនេះ ។

ព្រះវិញ្ញាណដ៏វិសុទ្ធនាំអោយយើងបានទទួល ព្រះពរជាច្រើនខាងព្រលឹងវិញ្ញាណ

ព្រះវិញ្ញាណដ៏វិសុទ្ធបញ្ជាក់ថា យើងជាកូនរបស់ព្រះជាម្ចាស់ និងមានសិទ្ធិទទួលព្រះពរខាងព្រលឹងវិញ្ញាណគ្រប់យ៉ាង ក្នុងព្រះ-គ្រីស្ត (យ៉ូហាន ១:១២, អេភេសូ ១:៥-៦) ។

ក្នុងអង្គព្រះគ្រីស្ត យើងបានទទួលព្រះពរគ្រប់យ៉ាង ផ្នែកខាងវិញ្ញាណ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។



ប្រាជ្ញា
(១ កូរិនថូស ១:៣០)

ការអត់ទោស
(អេភេសូ ១:៧)

ក្តីសុខសាន្ត
(យ៉ូហាន ១៤:២៧)

អំណរ
(១ ពេត្រុស ១:៨)

ការប្រោស ឱ្យបានវិសុទ្ធ
(១ កូរិនថូស ១:៣០)

បុទ្ធានុភាព
(កិច្ចការ ១:៨)

មរតកអស់កល្ប
(អេភេសូ ១:១៤)

ជីវិតបរិបូណ៌
(យ៉ូហាន ១០:១០)



ជ្បិតគ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ ស្ថិតនៅយ៉ាងពោរពេញក្នុងរូបកាយព្រះគ្រីស្ត ។ រីឯបងប្អូនក៏បានពោរពេញដូច្នោះដែរ ដោយរួមក្នុងអង្គព្រះគ្រីស្ត ដែលជាម្ចាស់លើវត្ថុសក្តិសិទ្ធិ និងលើអ្វីៗទាំងអស់ ដែលមានអំណាច ។

(កូឡូស ២:៩-១០)

សូមលើកតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង ដែលបានប្រោសប្រទានព្រះពរគ្រប់យ៉ាងផ្នែកខាងវិញ្ញាណពីស្ថានបរមសុខមកយើង ក្នុងអង្គព្រះគ្រីស្ត ។

(អេភេសូ ១:៣)

ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឫទ្ធានុភាពដល់យើង និងអំណោយទានដើម្បីអោយយើងផ្សាយដំណឹងល្អប្រាប់អ្នកដទៃ បំរើព្រះជាម្ចាស់ និងបំរើក្រុមជំនុំរបស់ព្រះអង្គ (កិច្ចការ ១:៨) ។

គោលបំណងរបស់ទីសំគាល់នៅក្នុងសម្ពន្ធមេត្រីថ្មី

នៅក្នុងសម្ពន្ធមេត្រីថ្មី ទីសំគាល់ជាការអស្ចារ្យដែលសំរាប់« បញ្ជាក់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ » (ម៉ាកុស ១៦:២០) ។ បានន័យថា ទីសំគាល់ជាសក្ខីភាពបង្ហាញថាដំណឹងល្អមកពីព្រះជាម្ចាស់ ។ ទីសំគាល់ដែលព្រះជាម្ចាស់ប្រទានអោយលោកម៉ូសេ ក៏មានគោលបំណងដូចគ្នានេះដែរ (សេរីភាព ៤:១-៩) ។ ការអស្ចារ្យប្រោសជំងឺរបស់ព្រះយេស៊ូ បង្ហាញអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដូចគ្នានេះដែរ ពេលដែលព្រះអម្ចាស់ ដេញអារក្សចេញពីមនុស្ស ព្រះអង្គបង្ហាញថា ព្រះរាជ្យរបស់ព្រះជាម្ចាស់បានមកដល់ហើយ ហើយមារសាតាំងត្រូវតែរត់ចេញ (ម៉ាថាយ ១១:២-៦, លូកា ១១:២០-២២, យ៉ូហាន ១០:២៥, ៣៧-៣៨) ។

...ជាបឋម ព្រះអម្ចាស់បានថ្លែងអំពីការសង្គ្រោះ ហើយអស់អ្នកដែលបានស្តាប់ ក៏បញ្ជាក់ប្រាប់យើងដែរ ។ ព្រះជាម្ចាស់ផ្តល់-សក្ខីភាពរួមជាមួយពួកគេ ដោយសំដែងទីសំគាល់ទ្ធិបាដិហារិយ៍ ការអស្ចារ្យគ្រប់យ៉ាង ព្រមទាំងចែកព្រះអំណោយទានរបស់ព្រះ-វិញ្ញាណដ៏វិសុទ្ធមក ស្របតាមព្រះហឫទ័យព្រះអង្គផង ។

(ហេប្រឺ ២:៣-៤)

- បើសិនជាព្រះគ្រីស្តគង់ក្នុងយើង យើងនឹងមានសេចក្តីស្រឡាញ់ និងសេចក្តីមេត្តារបស់ព្រះអង្គចំពោះមនុស្សដទៃ (ម៉ាថាយ ៩:៣៦, រ៉ូម ១២:១៥, ១ កូរិនថូស ១២:២៦) ។ យើងជួយមនុស្សដទៃទៀត ទៅតាមអំណោយទានរបស់យើង ។
- អំណោយទានទាំងអស់ សុទ្ធតែសំរាប់ថ្វាយសិរីល្អ និងសរសើរតម្កើងព្រះជាម្ចាស់ ហើយសំរាប់កសាងក្រុមជំនុំអោយរីកចំរើនឡើង និងពង្រីកព្រះរាជ្យរបស់ព្រះជាម្ចាស់ ។ យើងត្រូវស្វែងរក និង ប្រើអំណោយទានទាំងនេះ ដើម្បីសំរេចគោលបំណងនេះ ។ ព្រះជាម្ចាស់នឹងមិនប្រទានពរឱ្យយើងទេ បើសិនជាយើងមានបំណងចង់ប្រើអំណោយទានទាំងនេះ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។

ព្រះអំណោយទានរបស់ព្រះអង្គ រួមមានអំណោយទានជាគ្រីស្តទូត អ្នកថ្លែងព្រះបន្ទូល គ្រូគង្វាល គ្រូបង្រៀន អ្នកផ្សាយដំណឹងល្អ ការបំរើអ្នកដទៃ ការបង្រៀន ការលើកទឹកចិត្ត ការធ្វើអំណោយ ការដឹកនាំ ការបង្ហាញសេចក្តីមេត្តាករុណា ការនិយាយភាសាចំឡែកអស្ចារ្យ ការបកប្រែភាសាចំឡែកអស្ចារ្យ សេចក្តីប្រាជ្ញាចំណេះដឹង ការប្រោសជម្ងឺ ការអស្ចារ្យ និងអំណោយទានផ្សេងៗច្រើនទៀត (រ៉ូម ១២:៦-៨, ១ កូរិនថូស ១២:៧-១០, អេភេសូ ៤:១១-១២) ។

ព្រះបិតារបស់យើងប្រទានអំណោយទានផ្សេងៗដល់កូនរបស់ព្រះអង្គគ្រប់គ្នា ។ សូមយើងទូលសូមឱ្យព្រះអង្គប្រទានអំណោយទានដែលស្របទៅតាមព្រះហឫទ័យរបស់ព្រះអង្គ ហើយប្រើអំណោយទានទាំងនោះ ដើម្បីបំរើព្រះអង្គ ។

ផ្នែក ទី ២

ផលផ្លែរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

យោងទៅតាមកាឡាទី ៥:២២-២៣ ផលផ្លែនៃព្រះវិញ្ញាណ គឺ :

- **សេចក្តីស្រឡាញ់**
- **អំណរ**
- **សេចក្តីសុខសាន្ត**
- **ចិត្តអត់ធ្មត់**
- **ចិត្តសប្បុរស**
- **ចិត្តសន្តោសមេត្តា**
- **ចិត្តស្មោះត្រង់ (ជំនឿ)**
- **ចិត្តស្លូតបូត**
- **ការចេះទប់ចិត្តខ្លួនឯង**



របស់ខ្លួន ចូរចែកដោយចិត្តស្មោះសរ
អ្នកដែលដឹកនាំ ចូរដឹកនាំដោយចិត្ត
ខ្នះខ្នែង អ្នកដែលចែកទានដល់ជនក្រីក្រ
ចូរចែកអោយគេដោយចិត្តត្រេកអរ ។



(រ៉ូម ១២:៦-៨)

ព្រះវិញ្ញាណប្រោសប្រទានឱ្យម្នាក់ៗ សំដែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម គឺព្រះអង្គប្រទានអោយម្នាក់ចេះនិយាយប្រកបដោយប្រាជ្ញា ហើយព្រះវិញ្ញាណដដែលប្រទានអោយម្នាក់ទៀតចេះនិយាយ ដោយយល់គម្រោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ ។ ព្រះវិញ្ញាណដដែលប្រទានឱ្យម្នាក់ទៀតមានជំនឿ ព្រះវិញ្ញាណដដែលប្រទានឱ្យម្នាក់ទៀតចេះប្រោសមនុស្សអោយជាពីជំងឺ អោយម្នាក់ទៀតចេះធ្វើការអស្ចារ្យ អោយម្នាក់ទៀតចេះថ្លែងព្រះបន្ទូល ឱ្យម្នាក់ទៀតចេះស្ទង់មើលវិញ្ញាណល្អ ឬអាក្រក់ អោយម្នាក់ទៀតចេះនិយាយភាសាចំឡែកអស្ចារ្យ អោយម្នាក់ទៀតចេះបកប្រែន័យភាសាទាំងនោះ ។

(១ កូរិនថូស ១២:៧-១១)

អំណោយទានផ្សេងៗ

- ព្រះជាម្ចាស់ប្រទានអំណោយទាន តាមព្រះហឫទ័យរបស់ព្រះអង្គសំរាប់កសាងក្រុមជំនុំមួយអោយចំរើនឡើង (១ កូរិនថូស ១២:១៨, អេភេសូ ៤:៤-១៦) ។

- ព្រះជាម្ចាស់ប្រទានអំណោយទានផ្សេងៗអោយអ្នកជឿម្នាក់ៗ គឺមិនមែនគ្រប់គ្នាបានទទួលអំណោយទានដូចគ្នានោះទេ ។ អំណោយទានទាំងឡាយ ធ្វើអោយក្រុមជំនុំរីកចំរើនឡើង និងមានឯកភាព ពីព្រោះទាំងអស់គ្នារួមសហការជាមួយគ្នាដោយស្រុះស្រួលគ្នា (រ៉ូម ១២:៣-៨, ១ កូរិនថូស ១២:៧-៣១, អេភេសូ ៤:៤-១៣) ។

យើងមានព្រះអំណោយទានប្លែកៗពីគ្នា ស្របតាមព្រះហ-ទ័យប្រណីសន្តោស ដែលព្រះជាម្ចាស់ប្រទានមកយើង ។ ប្រសិនបើបងប្អូនណា ទទួលព្រះអំណោយទានខាងថ្លែងព្រះបន្ទូល ត្រូវថ្លែងអោយស្របតាមជំនឿ អ្នកណាទទួលព្រះអំណោយទានខាងបំរើ ចូរបំរើទៅ អ្នកណាទទួលព្រះ-អំណោយទានខាងបង្រៀន ចូរបង្រៀនទៅ អ្នកដែលលើកទឹកចិត្តបងប្អូន ចូរលើកទឹកចិត្តគេទៅ អ្នកដែលចែកទ្រព្យ

ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអំណោយទានផ្សេងៗដល់អ្នកជឿម្នាក់ៗ ក៏ប៉ុន្តែ ព្រះអង្គធ្វើអោយមាន**ផលឆ្លែ**ដូចគ្នានៅក្នុងពួកអ្នកជឿគ្រប់គ្នាទាំងអស់ ។ ការដែលយើងបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ បានន័យថាព្រះអង្គគ្រប់គ្រងជីវិតរបស់យើងជាប់ជានិច្ច ។

... ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ មកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង ។

(រ៉ូម ៥:៥)



ប្រពៃណីវិញ្ញាណរបស់យើងនៅរួមជាមួយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ។
(១ កូរិនថូស ៦:១៧)

ខ្ញុំជាដើមទំពាំងបាយជូរ
ឯអ្នករាល់គ្នាជាមែក ។
អ្នកណាស្ថិតនៅជាប់នឹងខ្ញុំហើយ
ខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះ
បង្កើតផលបានច្រើន ។ បើដាច់ពីខ្ញុំ
អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ ។
(យ៉ូហាន ១៥:១៥)

រីឯប្រាជ្ញាមកពីព្រះជាម្ចាស់វិញ...
ជាប្រាជ្ញាបរិសុទ្ធ បន្ទាប់មក ជាប្រាជ្ញាផ្តល់សន្តិភាព
មានអធ្យាស្រ័យ ទុកចិត្តគ្នា ពោរពេញទៅដោយ
ចិត្តមេត្តាករុណា និងបង្កើតផលល្អគ្រប់យ៉ាង
ឥតមានលំអៀង
ឥតមានពុតត្បុត ។
(យ៉ាកុប ៣:១៧)

ប៉ុន្តែ



ប្រសិនបើបងប្អូនមានចិត្តច្រណែនឈ្នានីស
និងមានចិត្តប្រណាំងប្រជែង...“ប្រាជ្ញា”
បែបនេះ ជាប្រាជ្ញារបស់លោកីយ៍
ប្រាជ្ញារបស់មនុស្ស និង
របស់អារក្ស ។
(យ៉ាកុប ៣:១៤-១៥)

ព្រះគ្រីស្តជាសិរសា
(អេភេសូ ៤:១៥)

គ្រូគង្វាល
(អេភេសូ ៤:១១)

អ្នកថ្លែងព្រះបន្ទូល
(អេភេសូ ៤:១១)

ការបំរើ
(រ៉ូម ១២:៧)

អ្នកដែលចែកទាន
ដល់ជនក្រីក្រ
(រ៉ូម ១២:៨)



អ្នកដែលចែក
ទ្រព្យសម្បត្តិរបស់ខ្លួន
(រ៉ូម ១២:៨)

គ្រីស្តទូត
(អេភេសូ ៤:១១)

អ្នកដែលលើកទឹកចិត្ត
(រ៉ូម ១២:៨)

គ្រូបង្រៀន
(អេភេសូ ៤:១១)

អ្នកផ្សាយដំណឹងល្អ
(អេភេសូ ៤:១១)

អ្នកដែលជីកនាំ
(រ៉ូម ១២:៨)

© Project WorldReach © SEAN

ព្រះវិញ្ញាណដ៏វិសុទ្ធបំពេញយើង ដើម្បីពង្រឹងជីវិតយើងក្នុងព្រះ-គ្រីស្ត ។ នៅក្នុងសៀវភៅកិច្ចការ មានកត់ត្រាច្រើនដងអំពីពួកសាវ័កត្រូវបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ សាជាថ្មីម្តងហើយម្តងទៀត ។ ពួកគេផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត ដោយចិត្តអង់អាចគ្រប់ពេល (កិច្ចការ ២:៤-១១, ៤:៨-១៤, ៤:៣១) ។

ព្រះជាម្ចាស់សន្យានឹងប្រទានទ្វានុភាពអោយយើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ។ តើទ្វានុភាពនេះសំរាប់ធ្វើអ្វី ? ។

ផ្នែក ទី ៤

អំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

អំណោយទានសំរាប់កសាងក្រុមជំនុំអោយចំរើនឡើង :

ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានអំណោយទានខាងព្រលឹងវិញ្ញាណមក (១ កូរិនថូស ១២:៤-៦) ។ ព្រះ-ជាម្ចាស់ប្រទានព្រះអំណោយទានរបស់ព្រះអង្គ មកក្រុមជំនុំទាំងមូល ។ រូបគំនូរនេះបង្ហាញអំពីអំណោយទានខ្លះក្នុងរូបកាយរបស់ព្រះគ្រីស្ត ។

សេចក្តីស្រឡាញ់



អ៊ីស្រាអែលអើយ ចូរស្តាប់ ! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់ ។ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក អោយអស់ពីចិត្តគំនិត អស់ពីស្មារតី និង អស់ពីកម្លាំងកាយ ។

(ទុតិយកថា ៦:៤-៥, ម៉ាថាយ ២២:៣៧-៣៨)

បើសិនជាបុរសម្នាក់មានស្ត្រីផ្សេងទៀត នោះគាត់មិនអាចស្រឡាញ់ភរិយារបស់ខ្លួនអស់ពីចិត្តទេ ។ ដូចគ្នានេះដែរ បើសិនជាយើងទុករបស់អ្វីៗ ឬ មនុស្សណាផ្សេងជាទីមួយនោះ យើងមិនអាចស្រឡាញ់ព្រះជាម្ចាស់តែមួយរបស់យើង ឱ្យអស់ពីចិត្តគំនិតបានទេ ។

ព្រះជាម្ចាស់សក្តិសមនឹងយើងថ្វាយបង្គំ និងគោរពយ៉ាងខ្ពង់ខ្ពស់បំផុត និងស្រឡាញ់អោយអស់ពីចិត្តគំនិត ។ ទោះបីជាព្រះអង្គបរិសុទ្ធបំផុតក៏ដោយ ក៏យើងអាចចូលទៅជួបព្រះអង្គផ្ទាល់ តាមរយៈព្រះយេស៊ូគ្រីស្ត ដែលជាព្រះអង្គសំរុះសំរួល និងព្រះសង្គ្រោះរបស់យើងដែរ នៅពេលដែលយើងពិតជាកែប្រែចិត្តគំនិតពីអំពើបាបនោះ ។

- នៅពេលដែលយើងថ្វាយបង្គំ យើងអធិស្ឋាន និងអរព្រះ-គុណព្រះជាម្ចាស់ដោយអំណរ (ទំនុកដំកើង ១៥០) ។
- កោតខ្លាច (អេសាយ ៦:១-៨) ។
- មានសណ្ដាប់ធ្នាប់ (១ កូរិនថូស ១៤:៣២-៣៣, ៤០) ។
- យើងបង្ហាញសេចក្ដីស្រឡាញ់របស់យើង ចំពោះព្រះគ្រីស្ដ ដោយប្រតិបត្តិតាមសេចក្ដីបង្គាប់របស់ព្រះអង្គ (យ៉ូហាន ១៤:១៥) ។

សេចក្ដីបង្គាប់សំខាន់បំផុតទីពីរ គឺ *«ត្រូវស្រឡាញ់បងប្អូនឯទៀតៗ អោយបានដូចស្រឡាញ់ខ្លួនឯង »* (ម៉ាថាយ ២២:៣៩) ។

យើងត្រូវបង្ហាញសេចក្ដីស្រឡាញ់ដោយសកម្មភាព មិនមែនដោយពាក្យសំដីប៉ុណ្ណោះទេ គឺតាមអំពើដែលយើងប្រព្រឹត្ត (១ យ៉ូហាន ៣:១៨) ។ ១ កូរិនថូស ១៣:១-១៣ រៀបរាប់អំពីសេចក្ដីស្រឡាញ់ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតអោយមានក្នុងចិត្តរបស់យើង ។



ព្រះបន្ទូលសន្យាអំពីព្រះវិញ្ញាណដ៏វិសុទ្ធ គឺសំរាប់អ្នកជឿលើព្រះគ្រីស្ដទាំងអស់ (កិច្ចការ ២:៣៨-៣៩, អេភេសូ ១:១៣) ។

ទ្វានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សំរាប់យើង**ផ្សាយដំណឹងល្អ**ថ្វាយព្រះគ្រីស្ដ ។ ការផ្សាយដំណឹងល្អរបស់យើងមានប្រសិទ្ធិភាពតែនៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយអ្នកដែលមិនទាន់ជឿបើកចិត្តជឿប៉ុណ្ណោះ (លូកា ២៤:៤៦-៤៩, យ៉ូហាន ១៦:៨, កិច្ចការ ១:៥-៨) ។

ប៉ុន្តែ អ្នករាល់គ្នានឹងទទួលទ្វានុភាពមួយ គឺទ្វានុភាពនៃព្រះ-វិញ្ញាណដ៏វិសុទ្ធ មកសណ្ឋិតលើអ្នករាល់គ្នា ។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី » ។ *លុះព្រះយេស៊ូមានព្រះបន្ទូលដូច្នោះរួចហើយ ហើយនៅពេលដែលក្រុមគ្រីស្តទូតកំពុងតែមើលព្រះអង្គ នោះព្រះជាម្ចាស់ក៏លើកព្រះអង្គឡើងទៅលើមេឃ ព្រមទាំងមានពពកមកបាំងព្រះអង្គបាត់ពីភ្នែកគេទៅ* ។

(កិច្ចការ ១:៨-៩)

ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថៃ រហូតដល់អវសានកាលនៃពិភពលោក ។

(ម៉ាថាយ ២៨:២០)

ការផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត :

ព្រះអម្ចាស់យេស៊ូយាងឡើងទៅស្ថានបរមសុខ ដើម្បីចាត់ព្រះ-វិញ្ញាណដ៏វិសុទ្ធអោយមកគង់ជាមួយយើង ។ ព្រះវិញ្ញាណដ៏វិសុទ្ធបំពេញយើង ដើម្បីអោយយើងអាចផ្សាយដំណឹងល្អ ប្រកបដោយទ្វានុភាព ។

អំណរ



អំណរដែលកើតមាន ដោយសារព្រះ
វិញ្ញាណរបស់ព្រះជាម្ចាស់ ជាអំណរដែលមានជាប់ជានិច្ច
ទោះជានៅក្នុងពេលដែលយើងជួប ទុក្ខលំបាកក៏ដោយ
(១ ថេស្សាឡូនិក ១:៦, យ៉ាកុប ១:២) ។

បងប្អូនមិនដែលបានឃើញព្រះអង្គទេ តែបងប្អូនស្រឡាញ់ព្រះអង្គ ទោះបីបងប្អូននៅតែពុំទាន់ឃើញព្រះអង្គក្តី ក៏បងប្អូនជឿលើព្រះ-អង្គ ហើយមានអំណរសប្បាយដ៏រុងរឿងរកថ្លែងពុំបាន ។

(១ ពេត្រុស ១:៨)

ចូរបងប្អូនអរសប្បាយ ដោយរួមជាមួយព្រះអម្ចាស់ជានិច្ច ខ្ញុំសូមជំរាបបងប្អូនម្តងទៀតថា÷ ចូរអរសប្បាយឡើង ! ។

(ភីលីព ៤:៤)

សេចក្តីសុខសាន្ត



សេចក្តីសុខសាន្តតែមួយដែលនៅស្ថិតស្ថេរជាប់ជានិច្ច គឺជាសេចក្តីសុខសាន្តដែលមកពីព្រះជាម្ចាស់ ។ គ្មានបញ្ហាណាអាចដកហូតសេចក្តីសុខសាន្តនេះពីយើងបានឡើយ ។

ខ្ញុំទុកសេចក្តីសុខសាន្តអោយអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំអោយអ្នករាល់គ្នា ។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់អោយនេះ មិនដូចសេចក្តីសុខសាន្ត ដែលមនុស្សលោកអោយទេ ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចអោយសោះ ។ (យ៉ូហាន ១៤:២៧)

ដើម្បីអោយយើងមានសេចក្តីសុខសាន្តមកពីព្រះជាម្ចាស់ យើងត្រូវមានមនសិការជ្រះថ្លា ។

ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។ (១ យ៉ូហាន ១:៩)

ដើម្បីអោយយើងមានសេចក្តីសុខសាន្ត យើងត្រូវមានសេចក្តីពិត និងត្រូវចេះសម្រុះសម្រួលនឹងអ្នកឯទៀតដែរ ។

(ម៉ាថាយ ៥:២១-២៦)

ផ្នែក ទី ៣

ឫទ្ធានុភាពសំរាប់ការផ្សាយដំណឹងល្អ

ឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ :

មុននឹងព្រះគ្រីស្តយាងឡើងទៅស្ថានបរមសុខ ព្រះអង្គបានសន្យានឹងពួកសិស្សរបស់ព្រះអង្គថា នឹងចាត់ *«ព្រះដ៏ជួយការពារមួយអង្គទៀត»* ឱ្យយាងមក ហើយព្រះអង្គមានបន្ទូលថា÷ *«ខ្ញុំនឹងមករកអ្នករាល់គ្នាវិញ»* ។

(យ៉ូហាន ១៤:១៦-១៨)

នៅប៉ុន្មានថៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជ ក្នុងព្រះ-វិញ្ញាណដ៏វិសុទ្ធវិញ ។

(កិច្ចការ ១:៥)

ឫទ្ធានុភាពដែលមកពីស្ថានសួគ៌នេះ គឺសំរាប់បំពេញមហាបណ្តាំរបស់ព្រះអង្គ ដែលអោយចេញទៅផ្សាយដំណឹងល្អ និងបង្កើតសាវ័កថ្វាយព្រះអង្គ ។

យើងអាចសំដែងការយល់ព្រម និងអំណររបស់យើងនៅក្នុងកម្មវិធីថ្វាយបង្គំ ដោយនិយាយថា÷ «អាម៉ែន» «សូមថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់» ឬ «ហាលេលូយ៉ា» (ដែលមានន័យថា «សូមសរសើរតម្កើងព្រះជាម្ចាស់») ។ ប៉ុន្តែ យើងមិនត្រូវនិយាយឃ្លាទាំងនេះដូចសត្វសេក ដោយមិនគិតពីន័យរបស់ឃ្លាទាំងនេះទេ (ម៉ាថាយ ៦:៧) ។

តើផលផ្លែណាខ្លះរបស់ព្រះវិញ្ញាណ ដែលអ្នកត្រូវបណ្តុះអោយមានកាន់តែខ្លាំងក្នុងជីវិតរបស់អ្នក ដោយការអធិស្ឋាន និងការអប់រំខ្លួនឯង ?

តើអ្នកត្រូវបណ្តុះ...

សេចក្តីស្រឡាញ់ឬ ? អំណរ ? សេចក្តីសុខសាន្ត ?

ចិត្តអត់ធ្មត់ ? ចិត្តសប្បុរស ? ចិត្តសន្តោសមេត្តា ?

ជំនឿ ? ចិត្តស្លូតបូត ? ការចេះទប់ចិត្តខ្លួនឯង ?

ចិត្តអត់ធ្មត់



ចិត្តអត់ធ្មត់ ដែលកើតពីព្រះវិញ្ញាណព្រះជាម្ចាស់ នាំអោយអាចប្រឈមមុខនឹងទុក្ខលំបាកដោយជំនឿ និង អំណរ ។ ចិត្តអត់ធ្មត់នាំឱ្យយើងមិនឆាប់ខឹង ។ ចិត្តអត់ធ្មត់មិនសង្កត់សង្កិន ឬ បង្ខិតបង្ខំអ្នកដទៃ ។ ការដែលយើងឆ្លងកាត់បញ្ហា និង ទុក្ខលំបាកច្រើន ធ្វើអោយយើងមានចិត្តអត់ធ្មត់គ្រប់យ៉ាង (កិច្ចការ ១៤:២២, រ៉ូម ៥:៣-៥, យ៉ាកុប ១:២-៤) ។

ចិត្តសប្បុរស



ចិត្តសប្បុរសនាំអោយយើងអាចមានសេចក្តីស្រឡាញ់ និងមិនធ្វើអោយអ្នកដទៃឈឺចាប់ ទោះជាអ្នកដទៃបង្កើរឿងមុនក៏ដោយ ។ ចិត្តសប្បុរសនាំអោយយើងអាចឆ្លើយទៅវិញ ដោយសេចក្តីមេត្តាអាណិត មិនមែនដោយកំហឹងទេ ។ ចិត្តសប្បុរសមិននាំអោយប្រើភាពញញឹមក្លែងក្លាយ «តែសំបកក្រៅ» នោះទេ ។

ព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ ជំរុញយើងអោយកែប្រែចិត្តគំនិត (រ៉ូម ២:៤) ។ ដូចគ្នានេះដែរ ចិត្តសប្បុរសដែលកើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធចេះអត់ទោស និងអាចទ្រាំទ្រអំពើខុសឆ្គង របស់អ្នកដទៃ ដោយសារសេចក្តីស្រឡាញ់ (កូឡូស ៣:១២-១៣) ។

ចិត្តសន្តោសមេត្តា



ចិត្តសន្តោសមេត្តាដែលកើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ជួយជំរុញយើងអោយធ្វើអំពើល្អ (ហេប្រឺ ១០:២៤) ។ ធ្វើជាគ្រីស្តជន មិនមែនបានន័យថា គ្រាន់តែទៅព្រះវិហារនោះទេ ។ តែយើងជាគ្រីស្តជន ត្រូវបំរើពួកអ្នកដែលមានការខ្វះខាត ហើយបំរើមនុស្សទាំងអស់ ដោយសារតែយើងស្រេកឃ្លានសេចក្តីសុចរិត និង ស្រឡាញ់ព្រះជាម្ចាស់ (ម៉ាថាយ ៥:៦) ។

ជំនឿរបស់យើងត្រូវបង្កើតផលផ្លែជាអំពើល្អ បើមិនដូច្នោះទេ នឹងក្លាយជាជំនឿស្លាប់ ហើយមិនអាចសង្គ្រោះយើងបានទេ (ម៉ាថាយ ២៥:៣១-៤៦, យ៉ាកុប ១:២២-២៧) ។

ចិត្តស្មោះត្រង់ (ជំនឿ)



ជំនឿធ្វើអោយយើងមានអ្វីៗ ដែលយើងសង្ឃឹមថា នឹងបាន និង ធ្វើអោយស្គាល់ជាក់ច្បាស់នូវអ្វីៗ ដែលយើងមើលពុំឃើញ ។

(ហេប្រឺ ១១:១)

អំណរជាបន្តរហូត ដោយសារអំណរដែលកើតពីព្រះវិញ្ញាណដ៏-វិសុទ្ធ ប៉ុន្តែ អំណរដែលកើតពីសាច់ឈាមសុទ្ធសាធ នឹងឆាប់ធ្វើអោយយើងធុញទ្រាន់ ។ យើងត្រូវគ្រប់គ្រងលើអារម្មណ៍ខាងសាច់ឈាមជាប់ជានិច្ច បើមិនដូច្នោះទេ អារម្មណ៍នោះនឹងដឹកនាំយើងអោយធ្លាក់ចុះ ។

យើងត្រូវត្រួតពិនិត្យគ្រប់គ្រងបំណងប្រាថ្នាសាច់ឈាមរបស់យើង។ អ្នកជឿដែលខ្សោយច្រើនតែធ្វើអ្វីៗតាមចិត្តរបស់ខ្លួន ប៉ុន្តែ អ្នកជឿរឹងមាំថ្វាយរូបកាយ ចិត្តគំនិត និងអារម្មណ៍របស់ខ្លួនទៅព្រះជា-ម្ចាស់ ទុកជាយញ្ញបូជាដ៏មានជីវិតរស់ ធ្វើដូចនេះ ទើបគេអាចធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន (រ៉ូម ១២:១-២) ។

ចំពោះបងប្អូន ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតនៅក្នុងបងប្អូន បងប្អូនមិនមែននៅខាងលោកីយ៍ទៀតទេ គឺនៅខាងព្រះ-វិញ្ញាណ ។ អ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ត អ្នកនោះមិនមែនជាកូនចៅរបស់ព្រះអង្គទេ ។

(រ៉ូម ៨:៩)

© Project WorldReach © SEAN

ការចេះទប់ចិត្តខ្លួនឯង



ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងអាចគ្រប់គ្រង
និងអាចទប់បង្ខន់បំណងប្រាថ្នា និង អារម្មណ៍របស់យើងបាន ។
ឧទាហរណ៍ ព្រះគ្រីស្តអាចនៅសៀមបាន នៅពេលដែលគេចោទ
ប្រកាន់ព្រះអង្គ ពេលគេកាត់ទោសព្រះអង្គ ។ ព្រះអង្គបានអត់
ទោសអោយពួកអ្នកដែលប្រឆាំងនឹងព្រះអង្គ ទោះជាព្រះអង្គមាន
អំណាចកំទេចពួកគេក៏ដោយ ។ ព្រះអង្គបានផ្ទុំលក់នៅពេលមាន
ខ្យល់ព្យុះក្នុងសមុទ្រ ហើយព្រះអង្គយាងទៅភ្នំកាល់វ៉ារី ដោយទឹក
ចិត្តសប់ជាទីបំផុត ។

អារម្មណ៍ដែលព្រះជាម្ចាស់ធ្វើអោយកើតមានឡើង អាចរីកចំរើន
កើនឡើង ដោយគ្មានធ្វើអោយមានផលអាក្រក់ដល់យើងទេ ។
សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត នាំឱ្យយើងអាចមានចិត្តស្រឡាញ់
កើនឡើងៗជាបន្តរហូត ។ ចំណែកឯសេចក្តីស្រឡាញ់ ដែលកើត
ពីសាច់ឈាម នាំអោយចិត្តយើងពុះពោរយ៉ាងឆាប់រហូតដល់យើង
លែងអាចគ្រប់គ្រងលើចិត្តគំនិតរបស់យើងបាន ។ យើងអាចមាន

*ដូច្នេះ យើងមិនចាប់អារម្មណ៍នឹងអ្វីៗដែលភ្នែកមើលឃើញឡើយ
គឺយើងចាប់អារម្មណ៍នឹងអ្វីៗ ដែលភ្នែកមើលមិនឃើញនោះវិញ
ដ្បិតអ្វីៗដែលភ្នែកមើលឃើញ នៅស្ថិតស្ថេរតែមួយរយៈប៉ុណ្ណោះ
តែអ្វីៗដែលភ្នែកមើលមិនឃើញ នៅស្ថិតស្ថេរអស់កល្បជានិច្ច ។*

(២ កូរិនថូស ៤:១៨)

ជំនឿពិតប្រាកដនាំអោយយើងស្វែងរកព្រះជាម្ចាស់÷ *«ឱព្រះជា-
ម្ចាស់អើយ ទូលបង្គំប្រាថ្នាចង់នៅជាមួយព្រះអង្គខ្លាំងណាស់ ដូច
សត្វក្តាន់ប្រាថ្នារកទឹកហូរ ។ ខ្ញុំស្រេកឃ្លានព្រះអម្ចាស់ គឺព្រះជា-
ម្ចាស់ដ៏មានព្រះជន្មគង់នៅ តើដល់កាលណា ទើបខ្ញុំអាចទៅជិត
ដើម្បីថ្វាយបង្គំព្រះអង្គបាន ?»* ។

(ទំនុកតម្កើង ៤២:១-២)

*... ជំនឿកើតមកពីសេចក្តី ដែលយើងបានស្តាប់ រីឯសេចក្តីដែល
យើងបានស្តាប់នោះ កើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ត ។*

(រ៉ូម ១០:១៧)

អ្នកជឿពិត ទុកចិត្តលើព្រះជាម្ចាស់ និង ព្រះបន្ទូលរបស់ព្រះអង្គ ។ ព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូ នាំយើងអោយអាចចូលទៅជិតព្រះជាម្ចាស់បាន ។ យើងទុកចិត្តទាំងស្រុងលើព្រះអង្គ ។

ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹង នៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថាប្រសិនបើយើងទូលសូមអ្វី ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្តាប់យើងជាមិនខាន ។

(១ យ៉ូហាន ៥:១៤)



ចិត្តស្លូតបូត

យើងដែលមានព្រះគ្រីស្តគង់ជាមួយ មានទឹកចិត្តស្លូតបូត គឺជាទឹកចិត្តសុភាពរាបសា ចេះបន្ទាបខ្លួនចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និង ចេះរក្សាសេចក្តីសុខជាមួយមនុស្សឯទៀត (ម៉ាថាយ ៥:៣-៥, ១៨:៣-៤, ភីលីព ២:១-១១, អេភេសូ ៤:១-៣) ។

មនុស្សអំនួតមានអារម្មណ៍ថា ខ្លួនត្រូវត្រួតត្រាលើអ្នកដទៃ ។ អ្នកនោះមានទឹកចិត្តកាច បិនរករឿងឈ្លោះ ហើយមិនចូលចិត្តរួមការងារទេ គឺចូលចិត្តប្រកួតប្រជែងវិញ ។

សាវ័កប៉ូលមានប្រសាសន៍ប្រាប់គ្រូគង្វាលធីម៉ូថេថា÷

រីឯអ្នកបំរើរបស់ព្រះអម្ចាស់ មិនត្រូវអោយមានការឈ្លោះប្រកែកគ្នាឡើយ ផ្ទុយទៅវិញ ត្រូវរួសរាយចំពោះមនុស្សទូទៅ ត្រូវចេះបង្រៀន និងអធ្យាស្រ័យដល់គេ ត្រូវមានចិត្តស្លូតបូត ប្រដៅពួកអ្នកប្រឆាំង...។

(២ ធីម៉ូថេ ២:២៤-២៥)

